ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ......... សហវ.........

រាជធានីភ្នំពេញ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៦

**គោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កម្មវត្ថុ:** ករណីសំណើសុំគោលការណ៍ឧបត្ថម្ភដល់ក្រុមមន្ត្រីវាយតម្លៃសម្រាប់ចុះវាយតម្លៃផ្ដល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា ។

**យោង:** របាយការណ៍កិច្ចប្រជុំអន្តរក្រសួងលើកទី២ រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៥ ស្ដីពីថវិកាសម្រាប់ឧបត្ថម្ភក្នុងការវាយតម្លៃផ្ដល់ការទទួលស្គាល់គុណភាពអប់រំ និងការកំណត់គោលរបបប្រាក់ឧបត្ថម្ភដល់មន្ត្រីវាយតម្លៃរបស់ក្រសួងអប់រំ យុវជន និងកីឡា ។

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានពិនិត្យ និងសម្រេចជាគោលការណ៍ដូចខាងក្រោម ÷

១ - **គោលការណ៍ឧបត្ថម្ភ** - អនុញ្ញាតផ្ដល់ជាប្រាក់ឧបត្ថម្ភជូនគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា សម្រាប់ចុះវាយតម្លៃគុណភាពអប់រំកម្រិតឧត្តមសិក្សា តាមនិយាមដូចខាងក្រោម ÷

១-១- <u>ប្រាក់ឧបត្ថម្ភសេវាចុះវាយតម្លៃនៅរាជធានីភ្នំពេញ ÷</u>

ក- ផ្ដល់ជូនទឹកប្រាក់យ៉ាងច្រើនចំនួន **២០ ៤០០ ០០០៛០០ (ម្ភៃលាន បួនរយពាន់រៀលគត់)** សម្រាប់ការចុះវាយតម្លៃផ្ដល់ការទទួលស្គាល់គុណភាពអប់រំ ក្នុងមួយគ្រឹះស្ថានឧត្តមសិក្សា ។

ខ- ផ្ដល់ជូនទឹកប្រាក់យ៉ាងច្រើនចំនួន **៥ ២០០ ០០០៛០០ (ប្រាំលាន ពីររយពាន់រៀលគត់)** សម្រាប់ការចុះវាយតម្លៃពាក់កណ្ដាលអាណត្តិ ក្នុងមួយគ្រឹះស្ថានឧត្តមសិក្សា ។

១-២- <u>ប្រាក់ឧបត្ថម្ភសេវាចុះវាយតម្លៃនៅតាមបណ្ដាខេត្ត ÷</u>

ក- ផ្ដល់ជូនទឹកប្រាក់យ៉ាងច្រើនចំនួន **៣៤ ៤០០ ០០០៛០០ (សាមសិបបួនលាន បួនរយពាន់រៀលគត់)** សម្រាប់ការចុះវាយតម្លៃផ្ដល់ការទទួលស្គាល់គុណភាពអប់រំ ក្នុងមួយគ្រឹះស្ថានឧត្តមសិក្សា ។

ខ- ផ្ដល់ជូនទឹកប្រាក់យ៉ាងច្រើនចំនួន **៨ ៧០០ ០០០៛០០ (ប្រាំបីលាន ប្រាំពីររយពាន់រៀលគត់)** សម្រាប់ការចុះវាយតម្លៃពាក់កណ្ដាលអាណត្តិ ក្នុងមួយគ្រឹះស្ថានឧត្តមសិក្សា ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

**២ - មុខសញ្ញាចំណាយ** - មុខសញ្ញាចំណាយខាងក្រោមនេះត្រូវបានអនុញ្ញាតនៅក្នុងកញ្ចប់ថវិកាដែលត្រូវផ្តល់ជូន ÷

- ប្រាក់ហោប៉ៅមន្ត្រីវាយតម្លៃ
- សោហ៊ុយហូបចុក ស្នាក់នៅ និងសោហ៊ុយធ្វើដំណើររបស់មន្ត្រីវាយតម្លៃ
- ចំណាយរដ្ឋបាលផ្សេងៗ ។

**៣ - នីតិវិធីចំណាយ និងកិច្ចបញ្ជិកា**

ក- <u>នីតិវិធីចំណាយ÷</u>

១- ក្រសួងអប់រំ យុវជន និងកីឡា (គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា) ត្រូវលើកស្នើសុំការចំណាយតែក្នុងវង្វង់ឥណទានថវិកាដែលបានគ្រោងទុកក្នុងផែនការឥណទានថវិកាប្រចាំឆ្នាំរបស់ខ្លួន ។

២- ដើម្បីអនុវត្តសកម្មភាពចុះវាយតម្លៃបានទាន់ពេលវេលា ក្រសួងអប់រំ យុវជន និងកីឡា (គណៈកម្មការធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា) ត្រូវអនុវត្តតាមនីតិវិធីចំណាយព្រមពោលគឺត្រូវរៀបចំគម្រោងអំពីចំនួនគ្រឹះស្ថានឧត្តមសិក្សាដែលត្រូវចុះវាយតម្លៃ គម្រោងចំណាយថវិកាស្របតាមគោលការណ៍របបឧបត្ថម្ភ រួចបោះផ្សាយអាណត្តិព្រមតែម្តង និងដាក់សំណើមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីពិនិត្យ និងសម្រេច។

ខ- <u>កិច្ចបញ្ជិកា ÷</u>

១- ដោយសារក្នុងឆ្នាំ២០១៦ ក្រសួងអប់រំ យុវជន និងកីឡាបានគ្រោងឥណទានថវិការបស់ខ្លួនសម្រាប់មុខសញ្ញាចំណាយនេះនៅក្នុងអនុគណនី ៦២០២៨ (ជំនួយសង្គមផ្សេងៗទៀត) ដូច្នេះ សម្រាប់ឆ្នាំ២០១៦ ការចំណាយនេះត្រូវកត់ត្រាចូលក្នុងអនុគណនី ៦២០២៨ ។ សម្រាប់ឆ្នាំ២០១៧ និងជាបន្តបន្ទាប់ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវគ្រោងឥណទានថវិកាសម្រាប់មុខសញ្ញាចំណាយនេះចូលទៅក្នុងអនុគណនី ៦១៩៨ (សោហ៊ុយនិងសេវាកម្មផ្សេងៗ)។

២- ឯកសារសក្ខីបត្រចំណាយ និងឯកសារយុត្តិកម្មផ្សេងៗលើការចំណាយនេះ ត្រូវរក្សាទុកនៅអង្គភាពដើម ដើម្បីជាកម្មវត្ថុនៃសវនកម្មក្រោយចំណាយរបស់ស្ថាប័នមានសមត្ថកិច្ច។

ទន្ទឹមនឹងនេះ ខ្ញុំសូមជម្រាបឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា ក្រសួងអប់រំ យុវជន និងកីឡាត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីរៀបចំប្រកាសអន្តរក្រសួងរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការគ្រប់គ្រងចំណូល និងការកំណត់ថវិកាសម្រាប់សេវាវាយតម្លៃគុណភាពអប់រំកម្រិតឧត្តមសិក្សា ឱ្យបានទាន់ពេលវេលា ដើម្បីឱ្យការអនុវត្តមានភាពរលូននិងមានប្រសិទ្ធភាពខ្ពស់ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី**មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

<u>**ចម្លងជូន ៖**</u>

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ក្រសួងមុខងារសាធារណៈ «ដើម្បីជូនជ្រាប»
-ឯកសារ-កាលប្បវត្តិ